# San Diego Unified School District

EUGENE BRUCKER EDUCATION CENTER
4100 Normal Street, San Diego, CA  92103-2682

Terry B. Grier, Ed.D.
អគ្គស្នងការក្រសួងអប់រំ

ខែ មេសា ឆ្នាំ ២០០៨

មាតាបិតា/អ្នកអាណាព្យាបាលសិស្សជាទីរាប់អាន:

ថ្ងៃទី ២៤ ខែ មិនា គឺជាថ្ងៃទីមួយដែលខ្ញុំចាប់ផ្តើមបំរើកិច្ចការជាអគ្គស្នងការអប់រំប្រចាំទីក្រុង San Diego ។ ខ្ញុំមានសេចក្តីរីករាយជាខ្លាំងដែលបានធ្វើការបំរើនៅទីក្រុង San Diego នេះ ។ ខ្ញុំបានចំណាយពេលវេលាជាច្រើនការពិនិត្យនៅតាមសាលារៀន - ជួបប្រជុំជាមួយសិស្សានុសិស្ស, លោកគ្រូ-អ្នកគ្រូ ព្រមទាំងលោកចាងហ្វាង ប្រចាំសាលារៀន - ខ្ញុំសង្ឃឹមថានឹងបានជួបជាមួយលោកអ្នកដែលជាមាតាបិតាជាច្រើនទៀតផងដែរ។

យោងទៅតាមមុខវិជ្ជាជិវៈរបស់ខ្ញុំធ្លាប់មានជំនាញការគឺ ខ្ញុំធ្លាប់ធ្វើជាគ្រូបង្រៀននៅតាមសាលាវិទ្យាល័យ, ជាគ្រូកីឡា, ចាងហ្វាងរង, ចាងហ្វាង ព្រមទាំងជាធ្វើការជាមួយអគ្គស្នងការអប់រំ។ ថ្មីៗនេះ ខ្ញុំបំរើការងារជាអគ្គស្នងការអប់រំប្រចាំស្រុក Guilford នារដ្ឋ North Carolina ហើយខ្ញុំបំរើការងារនេះចាប់តាំងពីឆ្នាំ ២០០០។ ហើយនាពេលនេះខ្ញុំមានកិត្តយសបំរើកិច្ចការជាអគ្គស្នងការអប់រំរបស់លោកអ្នក។

ខ្ញុំបានចំណាយពេលវេលាជាច្រើននាចុងសប្តាហ៍នេះនៅក្នុងទីក្រុង San Diego រហូតដល់ថ្ងៃទី ២៤ ខែ មិនា ដើម្បីជួបជាមួយសហគមន៍ ព្រមទាំងជួយដោះស្រាយបញ្ហាមួយដ៏សំខាន់ខាងផ្នែកថវិការដែលមាននៅក្នុងពេលនេះ។ ការស្នើសុំកាត់បន្ថយថវិការសំរាប់ក្រសួងអប់រំនៅក្នុងរដ្ឋ California ដែលអាចធ្វើអោយសិស្សរបស់យើងមានការខាតបង់។ លោកអ្នកជាមាតាបិតាភាគច្រើនមានអារម្មណ៏ដូចៗគ្នា។ យើងសូមអរគុណដល់លោកអ្នកដែលបានទូរស័ព្ទ និងផ្ញើលិខិត និង email ជូនទៅសមាជិសភា។ នាពេលឆាប់ៗខាងមុខនេះ យើងនឹងបើកការប្រជុំមួយស្តីអំពី ស្ថានការថវិការរបស់សាលារៀនយើង។ ខ្ញុំសូមលើកទឹកចិត្តលោកអ្នកចូលរួមប្រជុំដើម្បីស្តាប់ពត៌មានដ៏សំខាន់នេះ ព្រមទាំងធ្វើការសិក្សា និងសាកសួរពត៌មានទូទៅក្នុងការជួយសិស្សរបស់យើងទាំងអស់។

លោកអ្នកអាចជួយការបន្ថយថវិការរបស់សាលារៀនដោយពិនិត្យមើលឲ្យបានច្បាស់លាស់ថា កូនលោកអ្នកទៅរៀនអោយបានរាល់ថ្ងៃ ពេលមានសុខភាពល្អ។ ថវិការរបស់សាលារៀនរបស់យើងពឹងផ្អែកទៅលើសិត្ថិចំនួនសិស្សមករៀនជាប្រចាំថ្ងៃ ហើយនឹងបាត់បង់ថវិការចំនួន ៥០ដុល្លារក្នុងមួយថ្ងៃ បើសិស្សម្នាក់មិនមករៀន។ សូមគ្រោងធ្វើដំណើរ ពេលសាលារៀនបិតទ្វា ឬមានវិស្សមកាល។ ការធ្វើនេះអាចជួយដល់សាលារៀន និងសិស្សបាន។ តាមការសិក្សាស្រាវជ្រាវបង្ហាញអោយឃើញថា ពេលសិស្សមករៀនអោយបានរាល់ថ្ងៃនោះអាចធ្វើអោយសិស្សទទួលជ័យជំនះក្នុងការសិក្សាបាន។ លោកអ្នកអាចទទួលពត៌មានបានតាមប្រព័ន្ធវែបសាយរបស់សាលារៀនដែលមានគឺ http://www.sandi.net/programs/everydaycounts/index.html ។

ការមករៀនក្នុងពេលនេះគឺមានសារៈសំខាន់ជាទីបំផុតគឺអាចជួយសិស្សធ្វើការប្រឡងបានជ័យជំនះនារដូវស្លឹកឈើលាស់ខាងមុខនេះ។ លទ្ធផលនៃការប្រឡងអាចផ្តល់ជូនពត៌មានដល់មាតាបិតាអំពី ការសិក្សារបស់កូនបាន, ផ្តល់ពត៌មានដល់លោកគ្រូ-អ្នកគ្រូជួយដល់សិស្សតាមសេចក្តីត្រូវការ ព្រមទាំងជួយដល់បុគ្គលិកក្រសួងអប់រំស្វែងរកកម្មវិធីសំរាប់ជួយដល់សិស្សទាំងអស់សិក្សាបានដល់កំរិត។ ច្បាប់រដ្ឋ និងសហព័ន្ធប្រើប្រាស់លទ្ធផលនៃការប្រឡងនេះដើម្បីធ្វើការគ្រប់គ្រងសាលារៀន -- ជួយវាស់កំរិតកម្មវិធីសិក្សា និងសាលារៀន។

ខ្ញុំសង្ឃឹមថានឹងរួមសហការណ៏ជាមួយលោកអ្នក។ សូមអរគុណដល់លោកអ្នកដែលបានគាំទ្រកូនលោកអ្នសិក្សា - ព្រមទាំងបុគ្គលិកទូទៅ - និងជួយសិស្សនៅតាមផ្ទះ និងសាលារៀន។ ការរួមសហការណ៏ជាមួយក្រសួងអប់រំគឺមានសារៈសំខាន់ដែលអាចជួយសិស្សសិក្សាឲ្យមានជ័យជំនះ ហើយសិស្សត្រូវការជាចាំបាច់នាពេលនេះ។

ដោយក្តីរាក់ទាក់

Terry B. Grier, Ed.D.
អគ្គស្នងក្រសួងអប់រំប្រចាំក្រុង